ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

លេខ៖ ២៧៤ "ជ"

ចុះថ្ងៃ២២ ខែមេសា ឆ្នាំ២០២២

-សំណុំរឿងព្រហ្មទណ្ឌលេខ ៣៦៨១

ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២១

-សំណុំរឿងស៊ើបសួរលេខ ២៨០៨

ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២១

-សំណុំរឿងជំនុំជម្រះលេខ ៥៦៣

ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២

# សាលក្រម

## តាងនាមប្រជារាស្ត្រខ្មែរ

### សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង២ និង០០នាទីរសៀល នៅសាលសវនការទី៣ ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោក [redacted] ប្រធានក្រុមប្រឹក្សា

-លោក [redacted] ចៅក្រមប្រឹក្សា

-លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ។

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ។

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៦៨១ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] ចន្ត្រា ហៅអាជ្រូក ភេទប្រុស អាយុ ២១ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ[redacted] រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិ[redacted] រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] ស៊ីថា "រស់" ម្តាយឈ្មោះ [redacted] សុខនី "រស់" នីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។

ត្រូវបានចោទប្រកាន់ពីបទ៖ ហិង្សាមានស្ថានទម្ងន់ទោសដោយសារមរណៈភាពនៃជនរងគ្រោះ ប្រព្រឹត្តនៅផ្លូវលំ ភូមិចែងម៉ែង សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញកាលពីថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញាតិមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ។

២-ឈ្មោះ [redacted] ស៊ីលន ហៅលន ភេទប្រុស កើតថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៥ ជនជាតិខ្មែរ មុខរបរជាងឈើ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូ[redacted] រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅភូមិត្រពាំងទា សង្កាត់ត្រពាំងក្រសាំង ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ ធី "រស់" ម្តាយឈ្មោះ ថា "រស់" ជាអនីតិជន។

ត្រូវបានឃុំខ្លួនបណ្ដោះអាសន្ននៅមណ្ឌលអប់រំកែប្រែទី២(ម២) តាមរយៈដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦២៩៩ “ង១” ជ.ឃ.ជ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

៣-ឈ្មោះ [redacted]វិឃ្ស ហៅឃ្ស ភេទប្រុស កើតថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៥ ជនជាតិខ្មែរ មុខរបរ កម្មករសំណង់ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូ[redacted] រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅភូមិ[redacted] រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted]សាញ់ “រស់” ម្ដាយឈ្មោះ [redacted]វីន “រស់” អនីតិជន ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន។

ត្រូវបានឃុំខ្លួនបណ្ដោះអាសន្ននៅមណ្ឌលអប់រំកែប្រែទី២(ម២) តាមរយៈដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦២៩៩ “ង១” ជ.ឃ.ជ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

៤-ឈ្មោះ [redacted] សុខលីន ហៅលីន ភេទប្រុស កើតថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ[redacted] រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅភូ[redacted] រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] ប៊ុនធឿន “រស់” ម្ដាយឈ្មោះ [redacted] មុំ “រស់” នីតិជន ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន។

ត្រូវបានឃុំខ្លួនបណ្ដោះអាសន្ននៅមណ្ឌលអប់រំកែប្រែទី១(ម១) តាមរយៈដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦៣០០ “ង១” ជ.ឃ.ជ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

៥-ឈ្មោះ [redacted] រស្មី ហៅអាស្មី ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ[redacted]រាជធានីភ្នំពេញ ទីទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិ[redacted] រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ[redacted] ស៊ីថា “រស់” ម្ដាយឈ្មោះ[redacted] សុខនី “រស់” នីតិជន ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន។

៦-ឈ្មោះ[redacted]វ៉ាន់ណេត ហៅអាណេត ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ[redacted] រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិ[redacted]រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] សំណាង “រស់” ម្ដាយឈ្មោះ [redacted] ស្រីពៅ“រស់” នីតិជន ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន។

៧-ឈ្មោះ [redacted] ចន្ទវិចិត្រ ហៅអាចិត្រ ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូ[redacted] រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិ[redacted] រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ[redacted] សុផាន “រស់” ម្ដាយឈ្មោះ [redacted] សុខាន់ “រស់” នីតិជន ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន។

ត្រូវបានចោទប្រកាន់ពីបទ៖ សមគំនិតក្នុងអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារគុណភាពនៃជនរងគ្រោះ ប្រព្រឹត្តនៅផ្លូវលំ ភូមិចែងម៉ែង សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា២១៨ និងមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីនីត ភេទស្រី អាយុ ២០ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន ស្នាក់នៅផ្ទះជួល ភូមិចំការឪឡឹក សង្កាត់កាកាប២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

-លោកមេធាវី [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជាមេធាវីនៃក្រុមមេធាវី ស៊ី ភី អេច និងសហការី មានការិយាល័យនៅអាគារ ស៊ីភីអែល លេខ២៥ និង៦៣ បន្ទប់A ផ្លូវលេខ៣៤៨ កែង២០៤ សង្កាត់ទួលស្វាយព្រៃ២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ [redacted] ស៊ីលន ឈ្មោះ ឈ្មោះ [redacted] រស្មី ឈ្មោះ [redacted] ចន្ទ្រា ឈ្មោះ [redacted] វ៉ាន់ណេត និងឈ្មោះ [redacted] វិចិត្រ។

-លោកមេធាវី [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជាមេធាវីនៃក្រុមមេធាវី ស៊ីនហាន មានការិយាល័យនៅផ្សារទំនើបស៊ិតធីម៉ល ជាន់ទី៣ ផ្លូវ២១៧ (មហាវិថីមុនីវ៉េត) សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ មេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ [redacted] សុខលីន និងឈ្មោះ [redacted] វីយូ។

## អំពីអង្គហេតុ

តាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ដីកាសន្និដ្ឋានស្ថាពររបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងដីកាដំណោះស្រាយបញ្ជូនសំណុំរឿងទៅជំនុំជម្រះបានលើកឡើងនូវអង្គហេតុនៃរឿងក្ដីនេះថា៖ កាលពីថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង១៧ និង៤០នាទី ជនរងគ្រោះឈ្មោះ [redacted] ឃាង ភេទប្រុស និងឈ្មោះ [redacted] ថូស បានជិះម៉ូតូ ០១គ្រឿងឌុបគ្នាចេញពីផ្ទះជួល ទៅអង្គុយលេងនៅផ្លូវរថភ្លើង ភូមិចែងម៉ែង សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដោយសារម៉ូតូបែកកង់ជនរងគ្រោះក៏ចុះបណ្ដើ ពេលនោះក៏មានជនជាប់ចោទមួយក្រុមជិះម៉ូតូ ០៤គ្រឿង ដោយមាន ១.ឈ្មោះ [redacted] សុខលីន ភេទប្រុស ២.ឈ្មោះ [redacted] វីយូ ភេទប្រុស ៣.ឈ្មោះ [redacted] ស៊ីលន ភេទប្រុស ៤.ឈ្មោះ [redacted] រស្មី ភេទប្រុស ៥.ឈ្មោះ [redacted] ចន្ទ្រា ហៅ អាជ្រូក ភេទប្រុស ៦.ឈ្មោះ ណាង វ៉ាន់ណេត ភេទប្រុស និងឈ្មោះ [redacted] ច័ន្ទវិចិត្រ ភេទប្រុស បានចុះមកវាយជនរងគ្រោះ ដោយជនជាប់ចោទឈ្មោះ [redacted] ចន្ទ្រា ហៅជ្រូក បានយកកំណាត់ឈើជ្រុងវាយក្បាលមកជនរងគ្រោះឈ្មោះ [redacted] ឃាង ចំក្បាលពីក្រោយ។ បន្ទាប់មកក្រុមជនជាប់ចោទខាងលើក៏បានជិះម៉ូតូគេចខ្លួន ចំណែកឯជនរងគ្រោះឈ្មោះ [redacted] ឃាង បានស្លាប់ក្រោយពេលបងប្អូនបញ្ជូនទៅមន្ទីរពេទ្យ។ លុះមកដល់ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១ ឈ្មោះ [redacted] សុខលីន ២.ឈ្មោះ [redacted] វីយូ និងឈ្មោះ [redacted] ស៊ីលន ភេទប្រុស ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនបន្ទាប់ពីមានពាក្យបណ្ដឹងរបស់ឈ្មោះ [redacted] ស្រីនីត ត្រូវជាបងស្រីជនរងគ្រោះ។

-បានឃើញ របាយការណ៍សំយោគលេខ ១៨៥/២១ រ.ប.ក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២៥៣០ អ.យ.ឈ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១៤៤ អ.យ.ឈ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ២៥៦ "ង១" ជ.ង ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

**នាពេលសវនាការ**

១-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីនីត បានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងចៅក្រមស៊ើបសួរថា៖ ខ្លួនត្រូវជាបងស្រីបង្កើតរបស់ជនរងគ្រោះឈ្មោះ [redacted] ឃាង ភេទប្រុស អាយុ១៦ឆ្នាំ។ កាលពីថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង១៨ និង៣០នាទី ប្អូនប្រុសរបស់ខ្លួនឈ្មោះ [redacted] ឃាង បានជិះម៉ូតូចេញពីបន្ទប់ជួល ស្ថិតនៅភូមិចំការឪឡឹក សង្កាត់សំរោងក្រោម ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ មិនដឹងទៅទីណានោះទេ ចំណែកខ្លួនកំពុងធ្វើម្ហូបនៅបន្ទប់ជួលខាងលើ ក្រោយមកស្រាប់តែបងស្រីជីដូនមួយរបស់ខ្លួនឈ្មោះ ស្រីនី បានឆាតប្រាប់ខ្លួនថា ប្អូនប្រុសរបស់ខ្លួនត្រូវក្រុមជនជាប់ចោទវាយត្រូវរបួសធ្ងន់ ហើយឈ្មោះ ស្រីនី បានដឹកប្អូនប្រុសរបស់ខ្លួនទៅព្យាបាលនៅមន្ទីរពេទ្យព្រះកុសមៈ ពេលមកដល់មន្ទីរពេទ្យ ពេទ្យប្រាប់ថាប្អូនខ្លួនបាត់បង់ជីវិតបាត់ទៅហើយ ក្រោយមកក៏ឃើញសមត្ថកិច្ចមកដល់មន្ទីរពេទ្យ ហើយខ្លួនក៏ដាក់ពាក្យបណ្តឹង ដើម្បីឱ្យតុលាការចាត់ការតាមផ្លូវច្បាប់តែម្តង។ ពេលខ្លួនទៅមន្ទីរពេទ្យខ្លួនបានឃើញប្អូនប្រុសរបស់ខ្លួនត្រូវគេវាយបីក្រោយផុងលលាក្បាល។ ចំពោះជនជាប់ចោទដែលវាយប្អូនរបស់ខ្លួនមានចំនួន ០៨នាក់ ប៉ុន្តែខ្លួនពុំស្គាល់ឈ្មោះ និងពុំធ្លាប់ដឹងថាប្អូនប្រុសរបស់ខ្លួនមានទំនាស់ជាមួយអ្នកណាពីមុនមកទេ ម្យ៉ាងវិញទៀតប្អូនប្រុសរបស់ខ្លួនទើបតែឡើងមកពីស្រុកបានតែមួយថ្ងៃតែប៉ុណ្ណោះ។ ចំពោះឈ្មោះ [redacted] ចន្ទ្រា ឈ្មោះ [redacted] សុខលីន ឈ្មោះ [redacted] វិឡូ ឈ្មោះ [redacted] សីលន ឈ្មោះ [redacted] រស្មី ឈ្មោះ [redacted] វ៉ាន់ណោត និងឈ្មោះ [redacted] ច័ន្ទវិចិត្រ ខ្លួនពុំធ្លាប់ស្គាល់ពីមុនមកទេ។ សពរបស់ប្អូនខ្លួនឈ្មោះ [redacted] ឃាង បានធ្វើបុណ្យតាមប្រពៃណីហើយខ្លួនបានចំណាយប្រាក់ទាំងថ្លៃមន្ទីរពេទ្យ និងធ្វើបុណ្យសព សរុបអស់ប្រាក់ចំនួន ២០០០$ (ពីពាន់ដុល្លារអាមេរិក)។

២-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ទូស បានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងចៅក្រមស៊ើបសួរថា៖ ខ្លួនត្រូវជាបងជីដូនមួយរបស់ជនរងគ្រោះឈ្មោះ [redacted] ឃាង។ កាលពីថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង១៧ និង៤០នាទីរូបខ្លួន និងឈ្មោះ [redacted] ឃាង បានជិះម៉ូតូមួយគ្រឿងម៉ាក់ហុងដាសេ១២៥ ស៊េរីឆ្នាំ២០០៨ មិនចាំផ្លាកលេខដែលជារបស់ឈ្មោះ [redacted] ឃាង ចេញពីបន្ទប់ជួលស្ថិតនៅភូមិចំការឪឡឹក សង្កាត់សំរោងក្រោម ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ ក្នុងគោលបំណងអង្គុយលេងលើផ្លូវរថភ្លើង ស្ថិតនៅភូមិចែងម៉ែង សង្កាត់សំរោងក្រោម ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ តែដោយសាម៉ូតូបែកកងទើបរូបខ្លួន និងឈ្មោះ [redacted] ឃាង បានចុះបណ្តើប្រហែល១គីឡូម៉ែត្រ ក៏មានម៉ូតូជិះពីក្រោយចំនួន០៤គ្រឿង មានគ្នាប្រហែល ១០នាក់ជិះមក ហើយមានម៉ូតូ១គ្រឿងជិះ៣នាក់ បានចុះពីលើម៉ូតូមកវាយពួកខ្លួន ដោយជនជាប់ចោទម្នាក់បានយកកំណាត់ឈើជ្រុងមួយវាយក្បាលឈ្មោះ [redacted] ឃាង ចំពីក្រោយបណ្តាលឱ្យសន្លប់បាត់ស្មារតី ហើយពួកវាក៏ជិះគេចខ្លួនបាត់តែម្តង។ នៅថ្ងៃកើតហេតុខ្លួនឃើញជនជាប់ចោទម្នាក់ដែលមានកាន់ដំបងនោះជាអ្នកវាយឈ្មោះ សួន ឃាង រីឯបក្ខពួកផ្សេងទៀត ខ្លួនមិនបានដឹងថាពួកគេព្រួតវាយទៅលើឈ្មោះ [redacted] ឃាង ឬអត់ទេព្រោះខ្លួនបានរត់គេចខ្លួន ពុំបានមើលក្រោយឡើយ។ រូបខ្លួន និងឈ្មោះ [redacted] ឃាង ពុំធ្លាប់មានទំនាស់ជាមួយក្រុមជនជាប់ចោទទាំងនោះទេ។ ចំពោះឈ្មោះ [redacted] ចន្ទ្រា ឈ្មោះ [redacted] សុខលីន ឈ្មោះ [redacted] វិឡូ ឈ្មោះ [redacted] សីលន ឈ្មោះ [redacted] រស្មី ឈ្មោះ [redacted] វ៉ាន់ណោត និងឈ្មោះ [redacted] ច័ន្ទវិចិត្រ ខ្លួនពុំធ្លាប់ស្គាល់ពីមុនមកទេ។

៣-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] យ៉ា បានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា៖ មុនពេលកើតហេតុថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង១៨ និង៤៥នាទី រូបខ្លួនកំពុងតែអង្គុយលក់ដូរនៅភូមិចាក់ជ្រូក សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដោយកំពុងតែលក់ ស្រាប់តែឃើញក្មេងមួយក្រុមប្រហែលមានគ្នា ២០នាក់ជាង និងម៉ូតូប្រហែល១០គ្រឿង ប្រដាប់ដោយកាំបិទបន្តោ និងដំបងឈើ ដោយពេលនោះខ្លួនបានលឺពួកក្មេងៗនោះនិយាយថា នឹងហើយពួកអាដែង វៃទៅកាប់ទៅពួកអាដែង ពេលលឺដូចនោះខ្លួនមើលទៅ ស្រាប់តែ ឃើញក្រុមក្មេងនោះកាប់ និងវៃទៅលើម៉ូតូមួយគ្រឿងម៉ាក់ហុងដាឌ្រីម ស៊េរីឆ្នាំ២០១៦ ពណ៌ខ្មៅ ដោយពេលនោះក្រុមក្មេងបានកាប់ទៅលើម៉ូតូនោះ បណ្តាលឲ្យបែកក្បាំងមុខ និងពួកវាបានដកយកសោរម៉ូតូ ព្រមទាំងយកផ្លាក់លេខទៅជាមួយផង លុះបានប្រហែល២០នាទី ទើបម្ចាស់ម៉ូតូហុងដាឌ្រីម នោះមកយកម៉ូតូវិញ លុះប្រហែល១ម៉ោងក្រោយមកក៏ឃើញក្មេងប្រុសចំនួន ២នាក់បានបណ្តើម៉ូតូកាត់មុខផ្ទះ ដោយពេលនោះអ្នកជិតខាងខ្លួនបានសួរទៅក្មេងនោះថា ម៉ូតូកើតអី? ពួកគេបានឆ្លើយថា ម៉ូតូបែកកង់ ហើយពួកគាត់បន្តបណ្តើម៉ូតូទៅមុខទៀត លុះមួយសន្ទុះមកក៏លើនិយាយថា ក្មេងដែលបានបណ្តើម៉ូតូនោះត្រូវគេវៃស្លាប់ហើយ។

៤-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] រីយ៉ូ បានឆ្លើយសារភាពថា៖ ខ្លួនមិនទទួលយកបទចោទរបស់តំណាងអយ្យការទេ។ ពេលកើតហេតុនៅផ្ទះជាមួយឪពុកម្តាយ។ ក្រោយមកមានគេមកហៅ ថាមានការទៅសាកសួរ នៅប៉ុស្តិ៍ដោយចោទថាខ្លួនបានចូលរួមវាយជនរងគ្រោះ។ ខ្លួនស្គាល់ឈ្មោះ ជ្រូក ដែលជាអ្នកវាយគេ ជាអ្នកភូមិជាមួយគ្នា គាត់វាយបុរសម្នាក់មិនស្គាល់ឈ្មោះ។ ខ្លួនបានមិនឃើញផ្ទាល់ភ្នែកទេ ឯ០២នាក់ទៀតក៏មិនដឹងថាវាយគេ ឬអត់នោះទេ។ ពេលឆ្លើយនៅសមត្ថកិច្ច ខ្លួនក៏ឆ្លើយថាមិនបានប្រព្រឹត្តដែរ។ ពេលកើតហេតុខ្លួននៅកន្លែងផឹកឆ្ងាយពីកន្លែងកើតហេតុ ៣០ម៉ែត្រ ម៉ោង ៦ ទៅ ៧យប់ អត់មានភ្លើងទេ។ ខ្លួនមិនបានចូលរួមប្រព្រឹត្តទេ។ ចំពោះចម្លើយនៅប៉ូលីស ខ្លួនមិនទទួលស្គាល់ទេ ព្រោះប៉ូលីសបង្ខំឲ្យឆ្លើយ។ ចំណែកឯនៅតុលាការគេមិនបង្ខំទេ។ មុនពេលកើតហេតុខ្លួននៅជាមួយ គ្នីគ្នាជាមួយឈ្មោះ [redacted] អាស៊ុំ អាណោត ចិត្រ លន់ លីន ពេលកំពុងផឹកមិនមានអ្វីកើតឡើងទេ។ ពេលផឹកនោះឈ្មោះ ជ្រូក ជិះម៉ូតូទៅតែម្នាក់ឯង មិនដឹងទៅណាទេ។ ពេលកើតហេតុខ្លួនមិនចាំថាមានគេតេមកឈ្មោះ ជ្រូក ទេ។ ខ្លួនមិនបានទៅជាមួយឈ្មោះ ជ្រូក ទេ។ ពេលឈ្មោះ ជ្រូក ចេញទៅខ្លួននៅផឹកដដែល។ ខ្លួនមិនបានផ្តល់មធ្យោបាយអីដល់ឈ្មោះជ្រូកទេ។ ពេលសមត្ថកិច្ចសួរ គឺមិនបានបង្ខិតបង្ខំរូបខ្លួនទេ។ ខ្លួនមិនដែលប្រព្រឹត្តបទល្មើសទេ។ ខ្លួនក៏មិនបានដឹងថា ជ្រូក និងស្មី ទៅណាទេ។ អាស្មី ក៏បានជិះទៅក្រោយអាជ្រូកប្រហែល ២០នាទីតៅដោយខ្លួនឯង។ ក្រោយមកខ្លួនក៏ទៅផ្ទះដោយមិនបានទៅណាទេ។ ខ្លួនមិនមានម៉ូតូទេ ពេលផឹកស៊ីមាន ៣ម៉ូតូ ២គ្រឿងម៉ាក់ ហុងដា និង១គ្រឿងទៀតម៉ាក់ និច។ ម៉ូតូទាំងនោះជារបស់ឈ្មោះ ជ្រូក ស្មី និងចិត្រ។ ខ្លួនធ្លាប់ស្គាល់ឈ្មោះ ជ្រូក និងស្មី ព្រោះជាអ្នកភូមិជាមួយគ្នា តែមិនសូវជិតស្និតគ្នាទេ ពេលផឹកស៊ីជាមួយគ្នា ១ខែ៤ដង ។ មុនពេលកើតហេតុដឹងថាឈ្មោះ ស្មី និងអាជ្រូក មានជម្លោះជាមួយអ្នកផ្សេង។ ពេលផឹកស៊ីមានគ្នា ៧នាក់ ពេលផឹកខ្លួនមិនបានឃើញ អាជ្រូក កាន់ដំបងដែងទេ។ពេលផឹក ស្មី និងជ្រូក បានចេញទៅក្រៅ ចេញទៅ ៣ម៉ូតូបន្ទាប់មកខ្លួនក៏ទៅផ្ទះ។ ពេលទៅវិញខ្លួនមិនបានទទួលនាតពីឈ្មោះស្មី ទេ។ ខ្លួនមិនដឹងថាឈ្មោះ ជ្រូក ជិះម៉ូតូចេញទៅណាទេ។ ខ្ញុំមិនស្គាល់ជនរងគ្រោះទេ។

ពេលផឹកឈ្មោះ ស្មី ចេញទៅតែឯងក្រោយឈ្មោះ ជ្រូក ចេញទៅបានមួយសន្ទុះ។ ពេលកើតហេតុមានម៉ូតូ ៣ គ្រឿងចេញទៅដោយមានគ្នា ៤នាក់ ឈ្មោះជ្រូក ណេត ស្មី និងម៉ុន។ ខ្លួនមិនបានទៅទេ ពេលចេញទៅនោះមិនដឹងគេទៅណាទេ។ បន្ទាប់ពីបានស្តាប់ក្រឡាបញ្ជីអានកំណត់ហេតុចម្លើយរបស់ខ្លួននៅដំណាក់កាលមន្ត្រីនគបាលយុត្តិធម៌ ខ្លួនសូមទទួលយកចម្លើយនៅដំណាក់កាលសមត្ថកិច្ចវិញ។

៥-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]ស៊ីលន បានឆ្លើយសារភាពថា៖ ខ្លួនមិនបានធ្វើដូចការចោទប្រកាន់ទេ។ ឈ្មោះ ជ្រូក ជាអ្នកប្រព្រឹត្តដោយវាយទៅលើជនរងគ្រោះ។ ខ្លួនសស្គាល់ឈ្មោះ ស្មី ចិត្រ ណេត ពេលកើតហេតុខ្លួនមិនបាននៅកន្លែងកើតហេតុទេ។ ពេលនោះខ្លួននៅផឹកជាមួយឈ្មោះ ម៉ុន ស្មី ជ្រូក ណេត ចិត្រ និងវិឃ្ន នៅជាមួយគ្នាច្រើន មានច្រើនម៉ូតូមិនចាំទេ។ ផឹកប្រហែល ២ទៅ៣ម៉ោង ប្រហែល ៤ ម៉ោង ខ្លួនមិនចាំទេ។ ពេលនោះខ្លួនមិនបានដឹងថាឈ្មោះ ជ្រូក ទៅវាយគេទេ មិនបានឃើញឈ្មោះ ជ្រូក កាន់ដំបងនោះទេ។ ពេលជ្រូក មកវិញប្រាប់ថាទៅផ្ទះវិញ មិនបានប្រាប់អ្វីផ្សេងទៀតទេ។ ខ្លួនធ្លាប់ទៅអង្គុយលេងនៅផ្លូវរថភ្លើង និងធ្លាប់ផឹកនៅទីនោះ។ ខ្លួនមិនចាំចម្លើយពីមុនមកនោះទេ។ ខ្លួនសុំទទួលយកចម្លើយដែលបានឆ្លើយកាលពីមុន។ ខ្លួនមានអាយុ ១៧ឆ្នាំ។ នៅពេលផឹកស៊ីមានគ្នាច្រើនមិនចាំចំនួនទេ។ ពេលផឹកខ្លួនមិនដឹងថាមានអ្វីកើតឡើងទេ។ ខ្លួនក៏មិនដឹងថាឈ្មោះ ជ្រូក ទៅណាដែរ។ ពេលកើតហេតុឈ្មោះ ជ្រូក ណេត ចិត្រ និងឈ្មោះ ស្មី បានចេញទៅ ចំណែកឯឈ្មោះ វិឃ្ន មិនបានទៅទេ។ ពេលនោះខ្លួនចេញទៅតាមក្រោយចំនួន ៣នាក់ មិនចាំទេ។ ឈ្មោះ វិឃ្ន មិនបាននៅទេ។ ចេញទៅមាន ៤ម៉ូតូ ១ម៉ូតូជិះគ្នា ២នាក់ និង១ម៉ូតូទៀតជិះ ៣នាក់។ ខ្លួនអត់មានម៉ូតូទេ គឺជិះជាមួយគេ។ ខ្លួនមិនបានទៅកន្លែងកើតហេតុទេ។ ពេលទៅដល់ពាក់កណ្តាល់ផ្លូវក៏ត្រឡប់មកវិញ មិនបានឃើញគេវាយគ្នាទេ។ ពួកខ្លួនធ្លាប់ផឹកជាមួយគ្នាច្រើនដង។ ពេលនោះជិះម៉ូតូទៅជាមួយឈ្មោះ ជ្រូក នៅតាមផ្លូវជ្រូកបានរើសដំបងជ្រុង។ ខ្លួនមិនបានឃើញជ្រូកវាយគេទេ។ ខ្លួនបានឃើញឈ្មោះ ជ្រូក កាន់ដំបង មិនបានឃើញវាយដល់ទេ។ ពេលនោះជួបគ្នា ៥នាក់ហើយបានផឹកស៊ីជាមួយគ្នា។ ខ្លួនមិនបានដឹងថាអ្នកណាវាយគ្នាទេ ពេលនោះវាយគ្នា ២ ទៅ៣ក្រុម។ ពេលនោះឈ្មោះ ជ្រូក ជាអ្នកវាយគេឲ្យស្លាប់។ បន្ទាប់ពីបានស្តាប់ក្រឡា បញ្ជីអានកំណត់ហេតុចម្លើយរបស់ខ្លួននៅដំណាក់កាលមន្ត្រីនគបាលយុត្តធម៌ ខ្លួនសូមទទួលយកចម្លើយនៅដំណាក់កាលសមត្ថកិច្ចវិញ។

៦-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុខលីន បានឆ្លើយសារភាពថា៖ ខ្លួនស្គាល់២នាក់ក្រោយ (ឈ្មោះ ឃ្យូ និងលន)។ ខ្លួនមិនចាំនោះពេលកើតហេតុទេ។ ពេលនោះខ្លួនផឹកនៅខារ៉ាអូខេមានគ្នា ៤ទៅ ៥នាក់ ឈ្មោះ ណេត ចិត្រ ម៉ុន និងខ្លួន។ លុះម៉ោង ៤ទៅផឹកបន្តទៀត។ ពេលផឹកស៊ីនោះអត់មានគេវាយគ្នាទេ។ ខ្លួនមិនស្គាល់ជនរងគ្រោះទេ។ ខ្លួនស្គាល់ឈ្មោះ ជ្រូក តែមិនបានដើរជាមួយ និងមិនធ្លាប់ផឹកជាមួយគ្នាទេ។ ខ្លួនបានដឹងថាជ្រូកទៅវាយគេ តែមិនបានឃើញជ្រូកកាន់ដំបងទេ ហើយក៏មិនបានឃើញជ្រូកវាយគេដែរ។ ពេលខ្លួនផឹកនៅខារ៉ាអូខេមានគ្នា ៥នាក់ មិនបានទៅផឹកនៅទីណាទៀតទេ។ ខ្លួនមិនចាំចម្លើយដែលធ្លាប់ឆ្លើយនៅប៉ូលីស និងតុលាការទេ។ ចម្លើយនៅប៉ូលីសគឺគេបង្ខំឲ្យឆ្លើយទេ។ ខ្លួនមិនបានផឹកជាមួយឈ្មោះ ជ្រូក ទេ។ ខ្លួនទៅផឹកនៅវត្តត្រពាំងឈូក ហើយពេលនោះមានភ្លៀង។ ពេលផឹកនោះមិនបានដឹងថាមានរឿងអ្វីទេ។ ពេលទៅនោះមានគ្នា៤ ទៅ៥ម៉ូតូ និងអ្នកផ្សេងទៀតមិនស្គាល់ទេ។ ខ្លួនស្គាល់ វិឃ្ន ដែរមិនបានទៅផឹកទេ។ ឈ្មោះ

លន ក៏មិនបានទៅផឹកដែរ។ ពេលផឹកនៅត្រពាំងឈូកនោះឈ្មោះ ស្មី បានជិះម៉ូតូចេញទៅ។ ខ្លួនមិនបានទៅផឹកតជាមួយឈ្មោះ ចិត្រ និងណេតទៀតទេ។ ខ្លួនទៅផ្ទះមុនមិនបានដឹងទេថាឈ្មោះ ស្មី កាន់ដំបងទៅផ្លូវរថភ្លើងចេញពីវត្តត្រពាំងឈូក ខ្លួនជិហចេញទៅផ្សេង។ មុនពេលកើតហេតុផឹកមានគ្នាច្រើន។ ពេលនោះឈ្មោះ ជ្រូកចេញទៅមុន។ បន្ទាប់មកទៅផឹកនៅវត្តត្រពាំងឈូក។ ពេលនោះឈ្មោះ ស្មី ទៅជាមួយឈ្មោះ ជ្រូក ខ្លួនមិនបានទៅជាមួយគេទេ។ ខ្លួនមិនបានចូលរួមវាយគ្នាជាមួយគេទេ។ ពេលកើតហេតុខ្លួនមិនបាននៅជាមួយ លន និងវីយូទេ។ ខ្លួនផឹក២កន្លែង គឺនៅខាវ៉ាអូខេ និងនៅវត្តត្រពាំងឈូក និង១កន្លែងទៀតនៅផ្លូវរថភ្លើងដោយមិនបានផឹកជាមួយគ្នាទេ។ ខ្លួនឃើញ ស្មី កាន់ដំបងប៉ុន្តែមិនដឹងប៉ុណ្ណាទេ។ ឈ្មោះ ស្មី ជាបងប្រុសឈ្មោះ ជ្រូក។ ខ្លួនមិនធ្លាប់ប្រើប្រាស់គ្រឿងញៀនពីមុនមកទេ និងមិនដែលប្រព្រឹត្តបទល្មើសឡើយ។ បន្ទាប់ពីបានស្តាប់ក្រឡាបញ្ជីអានកំណត់ហេតុចម្លើយរបស់ខ្លួននៅដំណាក់កាលមន្ត្រីនគបាលយុត្តធម៌ ខ្លួនសូមទទួលយកចម្លើយនៅដំណាក់កាលសមត្ថកិច្ចវិញ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ យើងឃើញថាចម្លើយរបស់ជនជាប់ចោទដែលបានឆ្លើយពេលសវនការ ជនជាប់ចោទទាំង ០៣រូប ព្យាយាមឆ្លើយបង្វែរអង្គហេតុខុសពីការពិត ហើយយើងឃើញថាជនជាប់ចោទទាំងបីរូបនេះហាក់បីឆ្លើយបញ្ច្រាសគ្នាដោយឈ្មោះ លីន គឺឆ្លើយថាមិនបានផឹកនៅជុំគ្នាជាមួយនឹងជនជាប់ចោទឈ្មោះ វីយូ និងជនជាប់ចោទឈ្មោះ ស៊ីលន នោះទេ ក៏ប៉ុន្តែជនជាប់ចោទគឺនៅផឹកជាមួយជនជាប់ចោទឈ្មោះ ណេត និងបក្ខពួកដទៃទៀត ប៉ុន្តែជនជាប់ចោទឈ្មោះ វីយូ និងឈ្មោះ ស៊ីលន ឆ្លើយថានៅជាមួយនិងបក្ខពួកផ្សេងទៀតដែលមានឈ្មោះ វីយូ ឈ្មោះ ស្មី ឈ្មោះលន ដូចជាមួយឈ្មោះលីនដែរ នេះជាចំណុចមួយដែលយើងចាប់គួរអារម្មណ៍ថាតើហេតុអ្វីបានជាគាត់ព្យាយាមឆ្លើយបែបហ្នឹង? ទី២ យើងឃើញថានៅក្នុងពេលធ្វើដំណើរទៅប្រព្រឹត្តបទល្មើស បានន័យថាពេលជិះម៉ូតូចេញទៅកន្លែងកើតហេតុគឺតាមឆ្លើយបញ្ជាក់របស់ឈ្មោះ ស៊ីលន ក៏បានឃើញឈ្មោះ ជ្រូក ចុះរើសឈើជ្រុងនៅជិតផ្លូវរទេសភ្លើង ចំណែកឈ្មោះ លីន ក៏បានឃើញឃើញឈ្មោះ ស្មី ក៏រើសឈើជ្រុងនៅរ៉ាវរថភ្លើងដែរ សរុបជារួមមកជនជាប់ចោទទាំង០៣រូបនេះ ក៏ដូចជនជាប់ចោទដែលស្ថិតក្រោមការចោទប្រកាន់មួយចំនួនទៀតនោះគឺពិតជានៅជាមួយគ្នា ដូចនេះមានន័យថាពួកគាត់ទាំង០៣រូបដែលមានវត្តមាននៅសវនការនេះព្យាយាមឆ្លើយកុហកតុលាការតាំងពីដើមរហូតមក ហើយយើងពិនិត្យឃើញថាជនជាប់ចោទគឺពិតជាបានរួមដំណើរទៅជាមួយគ្នាយ៉ាងពិតប្រាកដមែន ទាស់តែជនជាប់ចោទខ្លះគាត់អះអាងថាគាត់បានត្រឡប់មកវិញពាក់កណ្តាលផ្លូវ នេះជាចម្លើយមួយដែលយើងគួរពិចារណាទាំងអស់គ្នាថាតើយើងគួរជឿចម្លើយរបស់ជនជាប់ចោទទេព្រោះជនជាប់ចោទបានឆ្លើយកុហកសឹងតែគ្រប់រឿង។

មួយទៀតយើងឃើញថា ជនរងគ្រោះត្រូវបានរងរបួសដោយដំបងឈើផុងលលាដ៏ក្បាលបណ្តាលឱ្យស្លាប់នៅពេលដឹកទៅមន្ទីរពេទ្យ យល់ឃើញថាវាពិតជាមានភាពស៊ីសង្វាក់គ្នាតាមអ្វីដែលជនជាប់ចោទទាំង០៣រូបបានលើឡើងថាបក្ខពួកខ្លួននោះគឺពិតជាបានកាន់ដំបងឈើពិតប្រាកដមែន ដូចច្នេះតំណាងអយ្យការយល់ឃើញថាជនជាប់ចោទទាំង០៣រូបដែលមានមុខនៅក្នុងសវនការ និងជនជាប់ចោទដែលត្រូវបានចោទប្រកាន់របស់តំណាងអយ្យការ និងចៅក្រមស៊ើបសួរនោះ គឺពិតជាបានទៅប្រព្រឹត្តបទល្មើសនៅទីកន្លែងនោះពិតប្រាកដមែន ហើយនៅក្នុងនេះយើងឃើញថាជនជាប់ចោទឈ្មោះ [redacted] ចន្ត្រា ហៅ ជ្រូក ត្រូវបានចោទប្រកាន់ថាជាជនផ្តើមដំបូងដែលបានប្រព្រឹត្តអំពើល្មើសនេះទៅលើជនរងគ្រោះ ដោយឡែកជនជាប់ចោទទាំងប្រាំមួយរូបទៀតគឺត្រូវបានចោទ

ប្រកាន់ពីបទសមគំនិតក្នុងអំពើហិង្សាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ។

ឆ្លងតាមការសួរដេញដោលនាពេលសវនាការ និងពិនិត្យភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង បានបង្ហាញឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] ចន្ត្រា ហៅ ជ្រូក ឈ្មោះ [redacted] សុខលីន ឈ្មោះ [redacted] វីយ្យូ ឈ្មោះ [redacted] ស៊ីលន ឈ្មោះ [redacted] រស្មី ឈ្មោះ [redacted] វ៉ាន់ណេត និងឈ្មោះ [redacted] ច័ន្ទវិចិត្រ បានប្រព្រឹត្តបទល្មើស ហិង្សាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ និងសមគំនិតក្នុងអំពើហិង្សាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ប្រព្រឹត្តនៅចំណុចផ្លូវលំ ភូមិចែងម៉ែង សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ និងមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ។ ដូច្នេះ តំណាងអយ្យការ សុំតម្កល់ការចោទប្រកាន់តាមដីកាដ្ឋានស្ថាពរលេខ ១៤៤ អ.យ.ឈ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកជាបណ្តឹងបានការដដែល និងប្តឹងសុំឱ្យតុលាការសម្រេចតាមផ្លូវច្បាប់។

**សេចក្តីសន្និដ្ឋានប្តឹងសុំរបស់លោកមេធាវី [redacted]**

ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វីយ្យូ ហៅយ្យូ និងឈ្មោះ [redacted] ស៊ីលន ហៅលន សូមធ្វើសេចក្តីសន្និដ្ឋានដូចតទៅ៖ ពាក់ជាមួយរឿងក្តីនេះហាក់ដូចជាមានការភ័ន្តច្រឡំដោយសារកូនក្តីរបស់ខ្លួនស្តាប់សំនួរមិនសូវបានច្បាស់។ ពេលកើតហេតុកូនក្តីរបស់ខ្លួនបានចូលរួមផឹកស៊ីជាមួយគ្នា មានគ្នា ៤នាក់ ផឹកមួយសន្ទុះឈ្មោះ ស្មី ក៏បានហៅទៅជួយឈ្មោះ ជ្រូក វាយគេ។ ប៉ុន្តែ កូនក្តីរបស់ខ្លួនមិនបានទៅនោះទេ ការពិតរឿងនេះឈ្មោះ ស្មី និងឈ្មោះជ្រូក បានរត់គេចខ្លួនបាត់ហើយ ដូចនេះមានតែចារីផ្ទាល់ទេជាអ្នកប្រព្រឹត្តដែលដឹងរឿងពិត ប៉ុន្តែបែរជាជនទាំងនេះរត់គេចខ្លួនបាត់។ ចំណែកសាក្សីក៏មិនបានឃើញថាកូនក្តីរបស់ខ្លួនចូលរួមប្រព្រឹត្តដែរ។ ជនដែលមានដីកាចាប់ខ្លួន ប៉ុន្តែមកទល់ពេលនេះតុលាការនៅមិនគាន់ចាប់ខ្លួនបានទេ។ ខ្លួនបានទទួលព័ត៌មានថាជនដែលមានវត្តមាននៅមូលដ្ឋានជម្ពូវ័ន្ត ប៉ុន្តែបែរជាសមត្ថកិច្ចមិនចាប់ខ្លួនទៅវិញ។ កូនក្តីរបស់ខ្លួនមិនបានផ្តល់មធ្យោបាយណាមួយទៅឱ្យចារីក្នុងការប្រព្រឹត្តបទល្មើសនោះទេ។ ដូចនេះការចោទប្រកាន់នេះហាក់ដូចជាអយុត្តិធម៌ចំពោះកូនក្តីខ្លួន។ ក្នុងរឿងនេះគួតែចាប់ជនដែលដើម្បីយកចម្លើយការពិត ប៉ុន្តែមកដល់ពេលនេះជនដែលបែរជាមកនៅខាងក្រៅ ធ្វើឱ្យកូនក្តីរបស់ខ្លួនទទួលទោសជំនួសទៅវិញ។ ដូចនេះ សូមតុលាការផ្តល់យុត្តិធម៌ដល់កូនក្តីរបស់ខ្លួន និងលើកលែងបទចោទមកលើកូនក្តីរបស់ខ្លួនផង។

**សេចក្តីសន្និដ្ឋានប្តឹងសុំរបស់លោកមេធាវី[redacted]**

ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុខលីន ហៅលីន ឈ្មោះ [redacted] រស្មី ហៅអាស្មី ឈ្មោះ [redacted] ចន្ទ្រា ហៅជ្រូក ឈ្មោះ [redacted] វ៉ាន់ណេត ហៅណេត និងឈ្មោះ [redacted] ច័ន្ទវិចិត្រ ហៅអាចិត្រ សូមធ្វើសេចក្តីសន្និដ្ឋានដូចតទៅ៖ យោងតាមការដេញដោល យោងតាមចម្លើយរបស់ជនជាប់ចោទទាំង០៣នាក់ដែលមានវត្តមាននៅក្នុងពេលសវនាការ បានបង្ហាញឱ្យឃើញថា កូនក្តីរបស់ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ដោយគ្រាន់តែបានផឹកស៊ីជាមួយគ្នា មិនបានសកម្មភាពវាយទៅលើជនរងគ្រោះនោះឡើយ ជាក់ស្តែងមិនមានអ្នកណាមួយបានឃើញ ឬបង្ហាញថាកូនក្តីរបស់ខ្លួនបានប្រព្រឹត្តបទល្មើសនោះឡើយ។ យោងតាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា រាល់វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។

ម្យ៉ាងវិញទៀត ក្នុងការស៊ើបអង្កេតមិនមានអ្វីដាក់បន្ទុកដល់ជនជាប់ចោទទេ ហើយក៏គ្មានភស្តុតាងណាមួយមកដាក់បន្ទុកលើកូនក្តីរបស់ខ្លួនឡើយ។ សូមតុលាការឱ្យរួចផុតពីបទចោទទាំងស្រុងចាប់ពីពេលនេះ និងដោះលែងកូនក្តីរបស់ខ្លួនឱ្យមានសេរីភាព។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] សុខលីន ឈ្មោះ [redacted] វីយូ និងឈ្មោះ [redacted] លីលន បាននិយាយសំដីចុងក្រោយបង្អស់ថា៖ ខ្លួនស្នើសុំឱ្យតុលាការ មេត្តាជួយបន្ធូបន្ថយទោសឱ្យខ្លួនផង ពីព្រោះខ្លួនបានដឹងកំហុសហើយ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ

-ក្រោយពីបានពិនិត្យឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## <u>សំអាងហេតុ</u>

- **អំពីអង្គហេតុនៃការចោទប្រកាន់លើឈ្មោះ [redacted] ចន្ត្រា ហៅ ជ្រូក ឈ្មោះ [redacted] សុខលីន ឈ្មោះ [redacted] វីយូ ឈ្មោះ [redacted] ស៊ីលន ឈ្មោះ [redacted] រស្មី ឈ្មោះ [redacted] វ៉ាន់ណេត និង ឈ្មោះ [redacted] ច័ន្ទវិចិត្រ**

១-យល់ឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] ចន្ត្រា ហៅ ជ្រូក ឈ្មោះ [redacted] សុខលីន ឈ្មោះ [redacted] វីយូ ឈ្មោះ [redacted] ស៊ីលន ឈ្មោះ [redacted] រស្មី ឈ្មោះ [redacted] វ៉ាន់ណេត និង ឈ្មោះ [redacted] ច័ន្ទវិចិត្រ ត្រូវបានចោទប្រកាន់ទៅតាមអង្គហេតុទាំងឡាយនៃការទទួលខុសត្រូវរបស់គាត់ ដែលមានក្នុងដីកាសន្និដ្ឋានស្ថាពរលេខ ១៩៤ អ.យ.ឈ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ២៥៦ "ង១" ដ.ដ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ដូចមានចែងនៅក្នុងមាត្រា២៩ និងមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ចំពោះអំពើទាំងឡាយដែលបានកើតឡើងកាលពីថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២១ ប្រព្រឹត្តនៅចំណុចផ្លូវលំ ភូមិចែងម៉ែង សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ។

២- យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ចន្ត្រា ហៅ ជ្រូក ឈ្មោះ [redacted] សុខលីន ឈ្មោះ [redacted] វីយូ ឈ្មោះ [redacted] ស៊ីលន ឈ្មោះ [redacted] រស្មី ឈ្មោះ [redacted] វ៉ាន់ណេត និង ឈ្មោះ [redacted] ច័ន្ទវិចិត្រ ត្រូវបានចោទប្រកាន់ថាពួកគាត់បានចូលរួមធ្វើសកម្មភាពវាយទៅលើជនរងគ្រោះបណ្តាលឱ្យស្លាប់បាត់បង់ជីវិត ដែលអំពើផ្ទុយជាមួយច្បាប់ ហើយដែលបង្ហាញឱ្យឃើញថា សកម្មភាពនេះបានធ្វើឱ្យប៉ះពាល់ដល់អាយុជីវិតរបស់ជនរងគ្រោះ ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម ហើយអំពើទាំងនេះបានធ្វើឱ្យមហាជនបានមើលឃើញថា ជាសកម្មភាពសាហាវឃោរឃៅក្នុងផ្តាច់ជីវិតជនរងគ្រោះ វាខុសនឹងទំនៀមទម្លាប់ប្រពៃណីដ៏ល្អផងដែរ

ផង់របស់ប្រទេសកម្ពុជា ហើយត្រូវបានដាក់អោយទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនៃបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពជនរងគ្រោះ និងបានចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទដោយអនុលោមតាមបញ្ញត្តិមាត្រា២៩ និងមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា។

- **អំពីអង្គហេតុទាក់ទងនឹងបទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពជនរងគ្រោះ និងបទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពជនរងគ្រោះ**

៣-ក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា កាលពីថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២១ សមត្ថកិច្ចរបស់អធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានកសាងសំណុំរឿងបញ្ជូនមកកាន់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដែលជនជាប់ចោទឈ្មោះ [redacted] ចន្ថា ហៅ ជ្រូក ចោទប្រកាន់ពីបទហិង្សាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ប្រព្រឹត្តនៅចំណុចផ្លូវលំ ភូមិចែងម៉ែង សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញាតិមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ និងជនជាប់ចោទឈ្មោះ ឈ្មោះ [redacted] សុខលីន ឈ្មោះ [redacted] វិឃ្ញ ឈ្មោះ [redacted] ស៊ីលន ឈ្មោះ [redacted] រស្មី ឈ្មោះ [redacted] វ៉ាន់ណេត និង ឈ្មោះ [redacted] ច័ន្ទវិចិត្រ ចោទប្រកាន់ពីបទសំគំនិតក្នុងអំពើហិង្សាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ប្រព្រឹត្តនៅចំណុចផ្លូវលំ ភូមិចែងម៉ែង សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញាតិមាត្រា២៩ និងមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ។

៤-យល់ឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] ចន្ថា ហៅជ្រូក ជាចារីដែលបានប្រព្រឹត្តបទល្មើសផ្ទាល់ និងបក្ខពួកផ្សេងទៀត ដែលមានឈ្មោះ [redacted] រស្មី ហៅអាស្មី ភេទប្រុស អាយុ ២៥ឆ្នាំ ឈ្មោះ ណាង វ៉ាន់ណេត ហៅអាណេត ភេទប្រុស អាយុ ២៤ឆ្នាំ និងឈ្មោះ [redacted] ចន្ទវិចិត្រ ហៅអាចិត្រ ភេទប្រុស អាយុ ២៤ឆ្នាំ បានរត់គេចខ្លួនបាត់ ដោយមិនបានចូលមកឆ្លើយបំភ្លឺជូនតុលាការឡើយ ដែលធ្វើឱ្យក្រុមប្រឹក្សាជំនុំជម្រះមិនទាន់មានមូលដ្ឋានក្នុងការសម្រេចសេចក្តីនៅឡើយ ដូច្នេះ គប្បីចាត់របៀបលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៦៨១ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១ ដើម្បីស្រាវជ្រាវបន្ថែមលើឈ្មោះ [redacted] ចន្ថា ហៅអាជ្រូក ភេទប្រុស អាយុ ២១ឆ្នាំ ឈ្មោះ [redacted] រស្មី ហៅអាស្មី ភេទប្រុស អាយុ ២៥ឆ្នាំ ឈ្មោះ ណាង វ៉ាន់ណេត ហៅអាណេត ភេទប្រុស អាយុ ២៤ឆ្នាំ និងឈ្មោះ [redacted] ចន្ទវិចិត្រ ហៅអាចិត្រ ភេទប្រុស អាយុ ២៤ឆ្នាំ ឱ្យបានពេញលេញ។

<u>**ហេតុដូច្នេះទើបវិនិច្ឆ័យសេចក្តី**</u>

**១-ចាត់របៀប**លើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៦៨១ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១ ដើម្បីស្រាវជ្រាវបន្ថែមលើឈ្មោះ [redacted] ចន្ថា ហៅអាជ្រូក ភេទប្រុស អាយុ ២១ឆ្នាំ ឈ្មោះ [redacted] រស្មី ហៅអាស្មី ភេទប្រុស អាយុ ២៥ឆ្នាំ ឈ្មោះ [redacted] វ៉ាន់ណេត ហៅអាណេត ភេទប្រុស អាយុ ២៤ឆ្នាំ និងឈ្មោះ [redacted] ចន្ទវិចិត្រ ហៅអាចិត្រ ភេទប្រុស អាយុ ២៤ឆ្នាំ ឱ្យបានពេញលេញ។

**២-ចាត់តាំង**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ជាចៅក្រមស៊ើបសួរលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៦៨១ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១។

**៣-រក្សា**ជនជាប់ចោទឈ្មោះ [redacted] ស៊ីលន ហៅលន ភេទប្រុស កើតថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៥

ឈ្មោះ [redacted] វិយូ ហៅយូ ភេទប្រុស កើតថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៥ និងឈ្មោះ [redacted] សុខលីន ហៅលីន ភេទប្រុស កើតថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២ នៅក្នុងឃុំរហូតដល់មានការសម្រេចជាថ្មី។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុខលីន ឈ្មោះ [redacted] វិយូ និងឈ្មោះ [redacted] ស៊ីលន និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីនីត ជនជាប់ចោទឈ្មោះ [redacted] ចន្ត្រា ហៅជ្រូក ឈ្មោះ [redacted] រស្មី ឈ្មោះ [redacted] វ៉ាន់ណេត និងឈ្មោះ [redacted] ច័ន្ទវិចិត្រ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និងត្រា |

[redacted]

---

**"<u>បានចម្លងត្រឹមត្រូវតាមច្បាប់ដើម</u>"**

ថ្ងៃសុក្រ ០៦រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**<u>បានឃើញ</u>**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]